DELGOSEA
Partnership for Democratic Local Governance in Southeast-Asia

# Transfer Concept
# (Khmer Version)

"Humane Relocation and Empowerment of Street Vendors",
Choam Chao Sangkat, Cambodia

The project is implemented by Choam Chao based on the best practice from Solo, Indonesia. For further information as well as the English short version of this document, please visit:
www.DELGOSEA.eu

You can also get in touch with the local contact for this project:
Sopheark Chhim, sopheark_chhim@yahoo.com

The content of this document is the responsibility of the respective author.
Version 2011.

This project is co-funded by the European Union.

A Project implemented by the consortium: Konrad-Adenauer-Stiftung e.V., Thailand Environment Institute (TEI), Local Government Development Foundation Inc. (LOGODEF), United Cities and Local Governments for Asia and Pacific (UCLG-ASPAC), Association of Indonesian Regency Governments (APKASI), Association of Cities of Vietnam (ACVN), and National League of Communes/Sangkats of the Kingdom of Cambodia (NLC/S).

Contact: Konrad-Adenauer-Stiftung – 5/F Cambridge Bldg., 108 Tordesillas crn. Gallardo sts. - Makati City, Manila - Philippines

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សំណើគម្រោងស្តីពីការអតិវឌ្ឍការផ្ទេរទស្សន:

# គម្រោងគ្រប់គ្រងអ្នកលក់ដូរតាមដងផ្លូវ

សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ឆ្នាំ ២០១១

# មាតិកា


អារម្ភកថា............................................................ ៣

សេចក្ដីផ្ដើម............................................................៤

ផែនទីសង្កាត់ចោមចៅ............................................................ ៥

**ផ្នែកទី១** : ការវិភាគស្ថានភាពបច្ចុប្បន្ន............................................................ ៥

១.១ ស្ថានភាពភូមិសាស្ត្រ ............................................................ ៥

១.២ ស្ថានភាពបច្ចុប្បន្ន............................................................ ៦

១.២.១ ផ្នែកសេដ្ឋកិច្ច............................................................ ៦

១.២.២ ផ្នែកសង្គមកិច្ច............................................................ ៧

១.២.៣ ផ្នែកធនធានធម្មជាតិ និងបរិស្ថាន............................................................ ៩

១.២.៤ ផ្នែកសេវាកម្មរដ្ឋបាល និង សន្តិសុខ............................................................ ៩

១.២.៥ ផ្នែកយេនឌ័រ............................................................ ១០

១.៣ បញ្ហាប្រឈមសំខាន់ៗ ............................................................ ១១

**ផ្នែកទី២** : គម្រោងគ្រប់គ្រងអ្នកលក់ដូរតាមដងផ្លូវ ............................................................ ១១

២.១ ទិសដៅគម្រោង ............................................................ ១១

២.២ លទ្ធផលរំពឹងទុក ............................................................ ១១

២.២.១ លទ្ធផលរំពឹងទុកទី១ ............................................................ ១១

២.២.២ លទ្ធផលរំពឹងទុកទី២ ............................................................ ១១

២.២.៣ លទ្ធផលរំពឹងទុកទី៣ ............................................................ ១២

២.២.៤ លទ្ធផលរំពឹងទុកទី៤ ............................................................ ១២

# អារម្ភកថា

ក្រុមប្រឹក្សាសង្កាត់អាណត្តិទី០២ បានប្រសូត្រឡើងដោយការបោះឆ្នោតថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៧ហើយបាន និងកំពុងដំណើរការរួមគ្នាបំរើប្រជាពលរដ្ឋជាទូទៅក្នុងសង្កាត់ ។ក្នុងដំណើរការបំពេញភារកិច្ចបំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋក្នុងសង្កាត់ និង អនុវត្តតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលក្រុមប្រឹក្សាសង្កាត់ បានរៀបចំដំណើរការ កសាងកម្មវិធីវិនិយោគរយះពេល ០១ឆ្នាំ (២០១១) ។ កម្មវិធីវិនិយោគសង្កាត់ដែលបានបង្កើតឡើងនេះមានសារះសំខាន់ណាស់ដើម្បីជួយតំរង់ទិសសង្កាត់រៀបចំ និង អនុវត្តគំពោងព្រមទាំងសកម្មភាពអភិវឌ្ឍន៍មូលដ្ឋានអោយឆ្លើយតបទៅ និង តំរូវការពិតប្រាកដ របស់ប្រជាពលរដ្ឋនៅក្នុងសង្កាត់ ពិសេសសំរាប់ណែនាំរាល់ការធ្វើសេចក្តីសំរេចចិត្តអំពីការងារអភិវឌ្ឍន៍សង្កាត់ ការរៀបចំកម្មវិធី វិនិយោគប្រចាំឆ្នាំរបស់សង្កាត់ផងដែរ ។

ឯកសារនេះបានកំណត់អំពីយុទ្ធសាស្រ្តជាមូលដ្ឋាន និង គោលដៅទាំងឡាយដែលក្រុមប្រឹក្សាសង្កាត់ទាំងមូលត្រូវពុះពារអោយបានសំរេចក្នុង ឆ្នាំ២០១១ ។

ក្នុងនាមក្រុមប្រឹក្សាសង្កាត់ចោមចៅអាណត្តិទី០២ សូមថ្លែងអំណរគុណចំពោះប្រជាពលរដ្ឋក្នុងសង្កាត់ដែលបានចូលរួមប្រជុំថ្នាក់ភូមិ និង ចូលរួមផ្តល់មតិយោបល់ដោយលើកឡើងអំពីបញ្ហាតំរូវការជាក់ស្តែងដែលបានជួបប្រទះ និង សេចក្តីត្រូវការអភិវឌ្ឍន៍នានា ។

ជាមួយនេះ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគណះកម្មាធិការកសាងផែនការ និង ថវិកាសង្កាត់ជនបង្គោលនានារបស់សង្កាត់ មន្ទ្រីសំរបសម្រួលខណ្ឌ រាជធានី តំណាងអង្គភាពរដ្ឋបាលមូលដ្ឋានអង្គការក្រៅរដ្ឋាភិបាល តំណាងសហគមន៍ដែលបានចូលរួមចំណែក និងគាំទ្រនៅក្នុងដំណើរការ នៃ ការកសាងកម្មវិធីវិនិយោគសង្កាត់នេះរហូតបានសំរេចលទ្ធផលជាស្ថាពរ ។

ក្នុងនាមក្រុមប្រឹក្សាសង្កាត់ចោមចៅ សូមផ្ញើនៅសេចក្តីសង្ឃឹមទុកចិត្តជាមុនលើស្មារតីចូលរួមចំណែកជួយអភិវឌ្ឍន៍ ពីមន្ទីរវិស័យជាម្ចាស់ជំនួយទាំងអស់ និង សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ។ ខ្ញុំសូមប្រសិទ្ធិពរជ័យបវរមហាប្រសើរជូនដល់អស់លោក លោកស្រី នាងកញ្ញា សប្បុរសជនដែលបានជួយគាំទ្រនូវគំពោងទាំងអស់របស់សង្កាត់ចោមចៅយើងខ្ញុំ អោយជួបប្រទះនៅសេចក្តីសុខជានិច្ចនិរន្តន៍តរៀងទៅ ។

# សេចក្ដីផ្ដើម

ក្រុមប្រឹក្សាសង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ បានរៀបចំកម្មវិធី វិនិយោគឆ្នាំ២០១១ ដោយយោងទៅតាមផែនការអភិវឌ្ឍន៍ សង្កាត់រយះពេល ០៥ឆ្នាំ និងយោងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាល ឃុំ/សង្កាត់ និង ប្រកាសអន្តរក្រសួងលេខ ២៤២៣ ប្រក ចុះថ្ងៃទី ០៣/០៧/២០០៧ របស់ក្រសួងមហាផ្ទៃ និង ក្រសួងផែនការ ស្ដីពីការកសាងផែនការ អភិវឌ្ឍន៍ ឃុំ/សង្កាត់ និងកម្មវិធី វិនិយោគ ឃុំ/សង្កាត់ ។

ក្រុមប្រឹក្សាសង្កាត់ចោមចៅ មានកាតព្វកិច្ចចាំបាច់បំផុតក្នុងការរៀបចំកម្មវិធី វិនិយោគសង្កាត់របស់ខ្លួន ដោយមានការចូលរួមយោបល់ពីប្រជាពលរដ្ឋដោយផ្ទាល់ ។ ការរៀបចំកម្មវិធី វិនិយោគសង្កាត់នេះឡើង គឺ ដើម្បីប្រមូលផ្ដុំ នូវសេចក្ដីត្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋក្នុងសង្កាត់ និង ធ្វើអោយមានការប្រសើរឡើងវិញនៅរាល់សេវាកម្មសង្គមលើគ្រប់វិស័យដើម្បីលើកកំពស់ជីវភាពរស់នៅ និង សុខុមាលភាពប្រជាពលរដ្ឋទាំងផ្នែកសំភារះ និងស្មារតីលើស្មួយការ ការពារច្បាប់ និង សិទ្ធិមនុស្ស ។ ការរួមផ្សំពីសក្ដានុភាពដ៏ធំធេងរបស់ប្រជាពលរដ្ឋ ពោល គឺ ការចូលរួមរបស់ប្រជាពលរដ្ឋ និង ការគៀងគរធនធាននានា ដើម្បីឆ្លើយតបទៅ និង សេចក្ដីត្រូវការជាអាទិភាពទាំងនេះ ។

កម្មវិធី វិនិយោគល្អ គឺ ជាកម្មវិធីវិនិយោគមួយដែលបញ្ចូលយុទ្ធសាស្រ្តដើម្បីសំរេចបាននូវគោលដៅអភិវឌ្ឍន៍ និង ឆ្លើយតបទៅ និង សេចក្ដីត្រូវការរបស់សហគមន៍មូលដ្ឋានដែលមានការទាក់ទងពាក់ព័ន្ធនានាអោយចាប់អារម្មណ៏គាំទ្រជួយកែសំរួលស្ថានភាព ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងសង្កាត់ ។

កម្មវិធី វិនិយោគសង្កាត់នេះ និង បរិយាយពីស្ថានភាពជាក់ស្ដែងរបស់សង្កាត់ចោមចៅ សេចក្ដីត្រូវការអភិវឌ្ឍន៍ គោលដៅអភិវឌ្ឍន៍ យុទ្ធសាស្រ្តអភិវឌ្ឍន៍ និង គំរោង ឬ សកម្មភាព ជាអាទិភាពរបស់សង្កាត់ចោមចៅ ដែលត្រូវការអនុវត្តនៅក្នុងរយះពេល ឆ្នាំ២០១១ ខាងមុខនេះ ។

# ផែនទីសង្កាត់ចោមចៅ




## ១. ការវិភាគស្ថានភាពបច្ចុប្បន្ន

### ១.១ ស្ថានភាពភូមិសាស្ត្រ

*សង្កាត់ចោមចៅស្ថិតនៅភាគខាងត្បូងឈាងខាងលិច ក្នុងខណ្ឌដង្កោ រាជធានីភ្នំពេញ មានដីចំនួន ២២៧០ ហិកតា មានព្រំប្រទល់ខាង ជើងទល់និងសង្កាត់សំរោងក្រោម និងសង្កាត់ត្រពាំងក្រសាំង ខាងត្បូងជាប់និងសង្កាត់ក្ជើង ធះរទះ សង្កាត់ពងទឹក សង្កាត់ព្រៃស និងសង្កាត់ព្រៃវែង ខាងកើតជាប់និង សង្កាត់កាកាប សង្កាត់ដង្កោ និងសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ ហើយ ព្រំប្រទល់ខាងលិចជាប់និងសង្កាត់ កន្ទោក។*

### ១.២. ស្ថានភាពបច្ចុប្បន្ន

### ១.២.១ <u>ផ្នែក សេដ្ឋកិច្ច</u>

*សង្កាត់ចោមចៅមានផ្ទៃដីសរុបចំនួន ២.២៧០ហិតា បែងចែកជា ២៧ភូមិ និង ៦ភូមិមិន*

ផ្លូវការ ដែលមានប្រជាពលរដ្ឋរស់នៅច្រើនកុះករ ភាគច្រើនសាលារាជធានីភ្នំពេញបានផ្ទេរមកពីតំបន់ផ្សេងៗ។ ផ្ទៃដីមួយចំនួនធំក្លាយជាតំបន់រោងចក្រ សហគ្រាស ឃ្លាំង និង សំណង់ផ្ទះល្វែង ដីនៅសល់មួយចំនួនតូចជាដីបង្កបង្កើតផល ។

សង្កាត់មានផ្សារលក់ដូរទ្រង់ទ្រាយធំចំនួន០៥ និង ផ្សារលក់ដូរទ្រង់ទ្រាយតូចចំនួន០៧កន្លែង មានផ្លូវជាតិ ០២ខ្សែឆ្លងកាត់សំរួលក្នុងដឹកជញ្ជូនសំភារៈ និង ការធ្វើដំណើរចេញចូលរបស់ប្រជាពលរដ្ឋ ។

ប្រជាពលរដ្ឋ៤០%ជាកម្មកររោងចក្រ ១៥% ជាមន្ត្រីរាជការ ២៥% ជាអ្នកប្រកបអាជីវកម្មលក់ដូរ ២០%ប្រកបរបរបង្កបង្កើនផល និងចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ ។

ផ្អែកតាមកត្តាខាងលើក្រុមប្រឹក្សាសង្កាត់មានលទ្ធភាពក្នុងការគៀងគរប្រភពទុនពីបណ្តាក្រុមហ៊ុន សប្បុរសជន ប្រជាពលរដ្ឋ ក្នុងការអភិវឌ្ឍន៍មូលដ្ឋាន ពិសេសលើការងារស្តារហេដ្ឋារចនាសម្ព័ន្ធ ជួសជុលផ្លូវថ្នល់ ស្តារប្រព័ន្ធលូបង្ហូរទឹកបានជាច្រើនខ្សែបង្កលក្ខណៈងាយស្រួលក្នុងការដោះស្រាយជីវភាពប្រជាពលរដ្ឋបានធូធារជាបណ្តើរៗ ។

**ទន្ទឹម និងមានការរីកចំរើនខាងលើ ក៏នៅមានខ្វះខាតដូចជា ៖**

ម្ចាស់រោងចក្រ សហគ្រាសមួយចំនួនមិនគោរពច្បាប់ការងារបណ្តាលអោយមានកម្មករធ្វើកូដកម្មតវ៉ាម្តងម្កាល ។

កំណើនប្រជាពលរដ្ឋហូរចូលមកពីបណ្តាខេត្តជាច្រើនដើម្បីស្វែងរកការងារធ្វើតាមបណ្តាពាងចក្រ។

**<u>ការងារបង្កបង្កើនផល</u>** : លើការងារបង្កបង្កើនផលទូទាំងសង្កាត់នៅមានកំរិតទាបនៅមានកំរិតទាបនៅឡើយដោយប្រជាកសិករយើងធ្វើស្រែគឺពឹងផ្អែកលើទឹកភ្លៀង ពេលជួបគ្រោះរាំងស្ងួតធ្វើអោយសន្ទូង និងសំណាបក្រៀមស្វិតខ្លោចងាប់ដោយសារខ្វះប្រភពទឹក និងប្រឡាយស្រោចស្រព ចំពោះទិន្នផលស្រូវនៅទាបដូចនេះតទៅអនាគតយើង និង ប្រឹងប្រែងបំផុសប្រជាកសិករបញ្ចូលនៅបច្ចេកវិទ្យាទំនើបពិសេសត្រូវប្រើពូជស្រូវដែលមានទិន្នផលខ្ពស់ ។

**<u>ការចិញ្ចឹមសត្វ</u>** : លើការងារចិញ្ចឹមសត្វក្នុងមូលដ្ឋានមានកំរិតទាប ដោយសារខ្វះខាតបច្ចេកទេសបសុព្យាបាល ពិសេសចំណីមានតំលៃខ្ពស់ដែលជាបញ្ហាចោទខ្លាំងលើការចិញ្ចឹមសត្វនេះយើងបានអ្នកបច្ចេកទេសមកផ្សព្វផ្សាយបណ្តុះបណ្តាលជាប្រចាំ ដល់ប្រជាពលរដ្ឋ ។

**<u>ឥណទាន</u>** : ជីវភាពរស់នៅប្រជាពលរដ្ឋក្នុងមូលដ្ឋាននៅមានកំរិតទាបនៅឡើយដូចនេះការខ្ចីប្រាក់ពីអង្គការផ្សេងៗ ក៏មានច្រើនជាហូរហែរ ដូចនេះអាជ្ញាធរដែនដីតែងតែជួយសំរួលសេវាកម្មជានិច្ចតាមតំរូវការប្រជាពលរដ្ឋ ។

-មានធានាគារឯកជនចំនួន៥កន្លែង ងាយស្រួល ដល់ ប្រជាពលរដ្ឋទំនាក់ទំនងខ្ចីប្រាក់

សំរាប់ប្រកបមុខរបរផ្សេងៗ ។

ចំពោះកត្តាផ្សេងទៀតដូចជាតំលៃប្រថាប់ត្រាលើបញ្ជីស្នាមអត្រានុកូលដ្ឋានមានកំរិតទាបណាស់ប្រៀបធៀបទៅ និង ការកសាងគំរោងវចនាសម្ពន្ធទាំងនេះ ។ រីឯអប្បហារលើការជួលផ្ទះដីធ្លីរបស់ប្រជាពលរដ្ឋ កំរៃកើង ឬ អាជីវកម្ម ឧស្សាហកម្មផ្សេងៗ ក៏ មិនទាន់មានការណែនាំពីថ្នាក់លើមកដែរ ។

**១.២.២ ផ្នែកសង្គមកិច្ច**

**__វិស័យអប់រំ__** : នៅក្នុងសង្កាត់ចោមចៅមានសាលាបឋមសិក្សាចំនួន៥កន្លែង អនុវិទ្យាល័យចំនួន២កន្លែង វិទ្យាល័យចំនួន ១កន្លែង ។

-នៅក្នុងសង្កាត់មានសាលាបង្រៀនភាសាឯកជន និង បត្តេយ្យ ចំនួន១៥សាលា ។

-មជ្ឈមណ្ឌលកុមារកំព្រាមានចំនួន៦កន្លែង ដែលទទួលចិញ្ចឹមបីបាច់ថែរក្សាកុមារកំព្រាពីគ្រប់មជ្ឈដ្ឋាន

-មជ្ឈមណ្ឌលកែប្រែផ្តាច់គ្រឿងញៀនមានចំនួន២កន្លែង ដែលទទួលអប់រំ ដល់អ្នកដែលប្រើប្រាស់គ្រឿងញៀនទាំងការស្នាក់នៅ និងព្យាបាល។

មជ្ឈមណ្ឌលសង្គមកិច្ចរាជធានីភ្នំពេញ ០១កន្លែង ស្ថិតនៅភូមិស្រែជំរៅ ទទួលអប់រំថែទាំដល់ជនអនាថា កុមារកំព្រា ។

ដោយមានការផ្សព្វផ្សាយពីសំណាក់គណៈកម្មាធិការកិច្ចការនារី និងកុមារអប់រំ ពីផលប្រយោជន៍ នៃ ចំណេះដឹង និង ការចុះឈ្មោះចូលរៀនដោយពុំមានការបង់ប្រាក់ ម្យ៉ាងទៀតមាតា បិតាសិស្សបានយកចិត្តទុកដាក់ និង ជំរុញយកកូនចូលរៀនជារៀងរាល់ឆ្នាំ ដូច្នេះសាលាបានទទួលសិស្សចុះឈ្មោះចូលរៀនបានយ៉ាងច្រើនកុះករ បើប្រៀបពីមួយឆ្នាំ ទៅ មួយឆ្នាំសិស្សមានការកើនឡើងជាលំដាប់ ។

ចំពោះអនក្ខរជនមួយចំនួនដែលមិនចេះអក្សរ ក្រុមប្រឹក្សាសង្កាត់ខិតខំទំនាក់ទំនងជាមួយមន្ទីរអប់រំ និងអង្គការនានា បើកថ្នាក់អក្ខរកម្មក្រៅប្រព័ន្ធដើម្បីអោយជនទាំងនោះបានចូលរៀន ។

ទោះបីជាមានការខិតខំប្រឹងប្រែងយ៉ាងណាក៏នៅមានចំណុចខ្វះខាតមួយចំនួនលើវិស័យអប់រំដូចជា ៖

-ក្មេងគ្រប់អាយុខ្វះមិនបានចូលរៀន សិស្សខ្វះមិនបានឆ្លងផុតកំរិតសិក្សាទី១ ពិសេសសិស្សស្រីដែលគ្រួសារមានជីវភាពក្រីក្រត្រូវបានឪពុក ម្តាយអោយឈប់រៀនដើម្បីជួយធ្វើការរកកំរៃបន្ថែមដើម្បីបង្គ្រប់សេចក្តីត្រូវការរបស់គ្រួសារ ។

-ដោយកំណើនសិស្សកើនឡើងជារៀងរាល់ឆ្នាំ ជាហេតុបណ្តាលអោយសាលាខ្វះបន្ទប់រៀនបច្ចុប្បន្នសាលាខ្វះក្នុងមួយថ្នាក់មានសិស្ស ពី៥០នាក់ ទៅ ៧០នាក់ ដូច្នេះក្រុមប្រឹក្សាសង្កាត់ខិតខំទំនាក់ទំនងជាមួយក្រសួងអប់រំ សប្បុរសជន អង្គការនានាជួយកសាងសាលាបន្ថែមបំពេញទៅ

តាមតំរូវការរបស់សិស្សដែលបានកើនឡើងអោយស្របទៅតាមស្តង់ដារបស់ក្រសួងអប់រំ ។

**វិស័យសុខាភិបាល** :  ពិតមែនតែក្នុងមូលដ្ឋានសង្កាត់ពុំមានមណ្ឌលសុខភាព ប៉ុន្តែភ្នាក់ងារសុខាភិបាលខណ្ឌចុះអប់រំ និងចាក់ថ្នាំការពារ ដល់កុមារ ដើរដាក់ថ្នាំអាបែតតាមបណ្តាភូមិគ្រប់គ្រួសារដើម្បីកំចាត់មូសខ្លា ផ្សព្វផ្សាយអំពីកិច្ចការ ពារជំងឺឆ្លងផ្សេងៗ  និង សុវត្ថិភាពចំណីអាហារ ។

-នៅក្នុងសង្កាត់មានគ្លីនិកឯកជនចំនួន០៥កន្លែងអាចទទួលពិនិត្យ និងព្យាបាល សង្គ្រោះប្រជាពលរដ្ឋបានទាន់ពេលវេលា ។

-ស្ត្រីភាគច្រើនបានយល់ពីសុខភាពពេលមានផ្ទៃពោះបានទៅពិនិត្យផ្ទៃពោះនៅមន្ទីរពេទ្យបានទៀងទាត់ និង សម្រាលកូនជាមួយឆ្មបដែលមានបច្ចេកទេសត្រឹមត្រូវ ។

-ទោះបីជាមានភាពងាយស្រួលដូចខាងលើ ក៏នៅជួបប្រទះផលលំបាក ដល់ប្រចាពលរដ្ឋដែលមានជីវភាពក្រីក្រខ្វះខាត ថវិកាសំរាប់ចូលសំរាកព្យាបាលជំងឺ និងសម្រាលកូននៅតាមគ្លីនិកឯកជន និងមន្ទីរពេទ្យ ។

-សេវាព្យាបាលមានតំលៃខ្ពស់  បណ្តាលអោយស្ត្រីសម្រាលកូនមួយចំនួនគ្មានលទ្ធភាពសម្រាលនៅមន្ទីរពេទ្យនោះទេ ។

-ជំរុញបង្កើតភ្នាក់ងារសុខភាពភូមិ និងរិះរកមធ្យោបាយបង្កើតមូលនិធិសំរាប់ទ្រទ្រង់ ដល់ស្ត្រី និងអ្នកជំងឺដែលមានជីវភាពក្រីក្រ ។

**វិស័យសាសនា** :  នៅក្នុងសង្កាត់មានវត្តអារាមចំនួន០៦វត្ត សំរាប់ពុទ្ធសាសន៍និកជនធ្វើបុណ្យទានតាមប្រពៃណីព្រះពុទ្ធសាសនាចំពោះសាសនាគ្រិះស្ត គឺ មានឃើញដើរផ្សព្វផ្សាយចែកចាយព្រះបន្ទូលតាមផ្លូវសាធារណះ និងបិទនៅតាមដើមឈើ និងវិហាចំនួន០៤ក្នុងសង្កាត់ចំពោះសាសនាដ៏ទៃទៀតពុំមានផ្សព្វផ្សាយអ្វីទេ ។

បច្ចុប្បន្នដោយមានការគាំទ្រពីសប្បុរសជន ប្រជាពលរដ្ឋបានចូលរួមវិភាគទានជាថវិកា និង សំភារះជួយជួសជុលកែលំអរតាមបណ្តាវត្តនិមួយៗដូចជា ជួសជុលព្រះវិហារ  សាងសង់សាលាឆាន់ សាលាបាលី កែលំអរសួនច្បារ និង ដាំដើមឈើជាផលប្រយោជន៍សំរាប់ឧបាសកឧបាសិកាចូលរួមធ្វើបុណ្យតាមប្រពៃណី លើកស្ទួយវិស័យសាសនាអោយមានការរីកចំរើនជាលំដាប់។

គ្រប់បណ្តាវត្តត្រូវបានបង្កើតគណៈកម្មាធិការ អាចារ្យវត្តជាអ្នកគ្រប់គ្រង និង ថែរក្សាទ្រព្យសម្បត្តិរបស់វត្ត និង បានពង្រឹងធម៌វិន័យតាមពុទ្ធឱវាទ នៃ ព្រះបរមគ្រូ នៃយើង ។

ទន្ទឹម និងការរីកចំរើនដូចខាងលើ ក៏ នៅមានចំណុចខ្វះខាតមួយចំនួនដូចជា គណៈកម្មការវត្តមួយចំនួនពុំទាន់បានសាមគ្គីគ្នាបានល្អ ជាហេតុបណ្តាលអោយការគ្រប់គ្រង និង កសាង

*សមិទ្ធិផល នូវមានភាពយឺតយ៉ាវ ។*

**១.២.៣ ផ្នែកធនធានធម្មជាតិ និងបរិស្ថាន**

*ដោយមានក្រុមហ៊ុនស៊ិនទ្រីទទួលខុសត្រូវប្រមូលសំរាមតាមទីផ្សារ និង ទីប្រជុំជនមួយចំនួនបានទាន់ពេលវេលាធ្វើអោយស្ថានភាពនៅទីនោះមានភាពល្អប្រសើរ ដោយឡែកទីតាំងដែលពុំមានក្រុមហ៊ុនដឹកសំរាមទេនោះយើងបានបំផុសប្រជាជលរដ្ឋអោយដឹកកប់ ឬដុត ។*

*ជាចំណុចខ្វះខាត ការទុកដាក់កាកដំណល់ឧស្សាហកម្ម និង ការសំណល់ផ្ទះបាយក៏មិនទាន់រៀបរយនៅឡើយ ទាមទារអោយប្រជាពលរដ្ឋយើងយល់ដឹងបានខ្ពស់ទៀត អាជ្ញាធរដែនដី និងខិតខំរៀបចំកែលំអសោភ័ណ្ឌភាពក្នុងមូលដ្ឋានអោយមានភាពស្រស់បំព្រង ។*

*-ការទុកដាក់កាកសំណល់រឹង (សំរាម និងកាកសំណល់រាវ) ក៏រៀបរយនៅមិនទាន់សុក្រិតដែរ ទាមទារអោយប្រជាពលរដ្ឋបានយល់ដឹងខ្ពស់ពីការងារសំអាតបរិស្ថាន ។*

*-បំផុសប្រជាពលរដ្ឋចូលរួមថែទាំដាំដើមឈើ តាមដងផ្លូវសាធារណៈ ទីវត្តអារាមអោយបានច្រើនកុះករដើម្បីកែលំអសោភ័ណ្ឌភាព និងម្ចប់មានខ្យល់អាកាសល្អ ។*

**១.២.៤ ផ្នែក រដ្ឋបាល និង សន្តិសុខ**

*-លើការងារផ្តល់សេវាលិខិតស្នាមរដ្ឋបាលពុំមានការកកស្ទះទុកអោយយឺតយ៉ាវហួសពេលវេលាទេ សង្កាត់បានរៀបចំទុកដាក់លិខិតស្នាមបានល្អត្រឹមត្រូវ ទៅតាមកិច្ចការរដ្ឋបាលណែនាំពីថ្នាក់លើ។*

*-ការចុះបញ្ជីអត្រានុកូលដ្ឋានយើងបានអនុវត្តចុះបញ្ជីកំណើត និង បញ្ជាក់កំណើតជូនប្រជាពលរដ្ឋបាន៩៩% ដោយឡែកទារកទើបកើតយើងបានធ្វើការចុះបញ្ជីកំណើតជាបន្តបន្ទាប់។*

*-នៅក្នុងឆ្នាំនេះយើងបានសាងសង់អាគាររដ្ឋបាលសង្កាត់ ១ខ្នង ដែលមានកំពស់ពីរជាន់តំរូវការចាំបាច់ក្នុងការបំរើសេវាកម្មពាក់ព័ន្ធផលប្រយោជន៍ជូនប្រជាពលរដ្ឋ និង ជាទីកន្លែងទុកដាក់លិខិតស្នាមបានល្អ និង គង់វង្ស។ ។*

*-លើការងារសន្តិសុខសុវត្ថិភាពសង្គមក្នុងមូលដ្ឋានសង្កាត់បានយកចិត្តទុកដាក់រៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវទីផ្សារបង្ក្រាបរាល់បទល្មើសផ្សេង។ ដូចជាចោរឆក់ លួច ប្រើអំពើហឹង្សា ក្រុមក្មេងទំនើង ការប្រើប្រាស់គ្រឿងញៀន ការជួញដូរផ្លូវភេទ ការជួញដូរកុមារ ការកេងប្រវ័ញ្ចកុមារ ល្បែងស៊ីសង និងឧប្បត្តិហេតុចរាចរ។*

*ក្នុងនាមគណ:បញ្ជាការឯកភាពសង្កាត់បានបង្កើតប៉ុស្តិ៍ការពារ ២៤ម៉ោង ពង្រឹងប្រជាការពារតាមភូមិចូលរួមយាមកាមការពារភូមិ និងផ្តល់ពត៌មានដល់សង្កាត់ទាន់ពេលវេលា។*

*-សង្កាត់បានផ្តល់វិទ្យុទាក់ទង ដល់មេភូមិទាំង៣០ ដើម្បីរាយការណ៍ជាបន្ទាន់នៅពេលមាន*

បទល្មើសកើតឡើងតាមបណ្តាភូមិនិមួយៗ ។

-ផ្សព្វផ្សាយគោលការណ៍ភូមិ/សង្កាត់មានសុវត្ថិភាព ដល់ ប្រជាពលរដ្ឋបានជ្រាប និង ចូលរួមសកម្មភាពការពារភូមិ បានរឹងមាំ ។

-ទន្ទឹម និងនោះដែរយើងមានចំណុចខ្វះខាត លើចំណុចគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋដែលចូលមកស្នាក់នៅតាមបណ្តាផ្ទះជួល ជាហេតុបណ្តាលអោយជនល្មើសឈ្លៀតឱកាសបង្កសកម្មភាពបាន។

-លើការងារចុះបញ្ជីកំណើត ដល់ទារកដែលទើប និង កើតមិនទាន់បានគ្រប់នៅឡើយដោយឪពុក ម្តាយមួយចំនួនមិនយកចិត្តទុកដាក់ និងយល់ពីសារៈសំខាន់ នៃ សំបុត្រកំណើត ។

### ១.២.៥ ផ្នែក យេនឌ័រ

-លើការងារយេនឌ័របច្ចុប្បន្នយើងបានដំណើរការគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិង កុមារដែលមានការចូលរួមពីគ្រប់ផ្នែកជំនាញសង្កាត់ក្នុងនោះដែរ ក៏មានសមាសភាព លោក លោកស្រីមេភូមិ និង សមាជិកភូមិចូលរួមផងដែរ បានជួយផ្សព្វផ្សាយ នូវខ្លឹមសារសំខាន់ៗ ដែលណាក់ព័ន្ធ និង ស្ត្រីដូចខាងក្រោម :

អប់រំផ្សព្វផ្សាយលើកកំពស់មាតា និង ទារក

-អប់រំផ្សព្វផ្សាយលើកកំពស់អនាម័យមូលដ្ឋាន

-អប់រំផ្សព្វផ្សាយលើកកំពស់សមភាពយេនឌ័រ

-កម្មវិធីពន្យាកំណើត

-ច្បាប់ប្រឆាំងអំពើហឹង្សាក្នុងគ្រួសារ

-តួនាទីស្ត្រីក្នុងកិច្ចអភិវឌ្ឍន៍មូលដ្ឋាន

-ជាពិសេសចូលរួមដោះស្រាយទំនាស់ផ្សេងៗ ដែលកើតឡើងក្នុងគ្រួសារនិមួយៗទាន់ពេលវេលា ទប់ស្កាត់បានជាបណ្តើរៗ រាល់អំពើហឹង្សាក្នុងគ្រួសារ ។

ទន្ទឹម និងមានការរីកចំរើនខាងលើ ក៏នៅមានចំណុចខ្វះខាត :

-នៅមានអំពើហឹង្សាក្នុងគ្រួសារមួយចំនួនដែលបង្កឡើងទៀតបណ្តាលមកពីភាពក្រីក្រ ការប្រើប្រាស់ គ្រឿងស្រវឹង ល្បែងស៊ីសង ។

-ស្ត្រីមួយចំនួនមិនបានយកចិត្តទុកដាក់ចូលរួមបញ្ចេញយោបល់ការងារកសាងផែនការអភិវឌ្ឍន៍មូលដ្ឋាននៅឡើយ។

-ខ្វះការអប់រំណែនាំដល់កូន នូវការគោរពសីលធម៌ សុជីវធម៌ ទំនៀមទំលាប់ប្រពៃណីខ្មែរ។

-គ្រួសារមួយចំនួនមិនបានថែទាំ និងជំរុញអោយកូនចូលសាលារៀន ដោយផ្អែកលើជីវភាពក្រីក្រ។

### ១.៣ បញ្ហាប្រឈមសំខាន់ៗ

-លំហូរប្រជាពលរដ្ឋ ពីខេត្តនានាចូលមករស់នៅ និងប្រកបរបររកសុ នៅក្នុងសង្កាត់

-ម្ចាស់ពេងចក្រសហគ្រាសមិនគោរពច្បាប់

-ការបំពុលបរិស្ថាន ដោយសារការចោលកាកសំណល់រឹង និងរាវពីពេងចក្រសហគ្រាស

-ការលក់ដូរតាមដងផ្លូវគ្មានសណ្តាប់ធ្នាប់ ធ្វើអោយខូចបរិស្ថាន និងបង្កអោយមានគ្រោះថ្នាក់ចរាចរណ៍

## ២. គម្រោងគ្រប់គ្រងអ្នកលក់ដូរតាមដងផ្លូវ

### ២.១ ទិសដៅគម្រោង

ចូលរួមលើកស្ទួយការវិនិយោគ លើកកម្ពស់គុណភាពជីវិត និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងសង្កាត់តាមរយៈការធ្វើអោយប្រសើរឡើងនូវសណ្តាប់ធ្នាប់ បរិស្ថាន សន្តិសុខ និងអនាម័យតាមដងផ្លូវ និងតាមទីសាធារណៈ។

### ២.២ លទ្ធផលរំពឹងទុក

**២.២.១ លទ្ធផលរំពឹងទុកទី១** ទីតាំងអ្នកលក់ដូរអនាធិបតេយ្យ ត្រូវបានរៀបចំសមស្រប

សកម្មភាព១ ស្រង់ស្ថិតិចំនួនផ្សារនៅក្នុងសង្កាត់

សកម្មភាព២ ស្រង់ស្ថិតិអ្នកលក់ដូរចល័ត អ្នកដួលផ្ទះគេ និងអ្នកលក់ដូរតាមរដូវកាល

សកម្មភាព៣ កំណត់ទីតាំង និងម្ចាស់ទីតាំងផ្សារ

សកម្មភាព៤ ជ្រើសរើសទីតាំងផ្សារសាកល្បង

**២.២.២ លទ្ធផលរំពឹងទុកទី២** តំលៃតូបនៅក្នុងផ្សារត្រូវបានកែសំរួល អាចទទួលយកបាន

សកម្មភាព១ ជួបប្រជុំជាមួយអ្នកពាក់ព័ន្ធ ម្ចាស់ទីតាំង និងអ្នកលក់ដូរ

សកម្មភាព២ ជួបពិភាក្សាជាមួយរដ្ឋបាលខណ្ឌ សាលារាជធានីភ្នំពេញ លើការវិនិយោគទីតាំងផ្សារ

សកម្មភាព៣ ផ្សព្វផ្សាយព័ត៌មាន និងអប់រំអ្នកទិញអោយចូលទិញនៅក្នុងផ្សារ

សកម្មភាព៤ េចំគណកម្មការទទួលខុសត្រូវសណ្តាប់ធ្នាប់ និងសន្តិសុខ

**២.២.៣ លទ្ធផលរំពឹងទុកទី៣** ទុន និងសមត្ថភាពត្រូវបានផ្តល់ដល់អ្នកលក់ដូរក្រីក្រ និងអ្នកខ្វះខាតទុន

សកម្មភាព១ ចងក្រងអ្នកលក់ដូរខ្វះទុន

សកម្មភាព២ បណ្តុះបណ្តាលជំនួញអាជីវកម្មខ្នាតតូច

សកម្មភាព៣ ចរចារជាមួយម្ចាស់ទីតាំងដើម្បីបញ្ចុះតម្លៃឈ្នួល

សកម្មភាព៤ ផ្សព្វផ្សាយព័ត៌មាន អប់រំ និងលើកទឹកចិត្តអ្នកទិញឱ្យចូលទិញក្នុងផ្សារ

**២.២.៤ លទ្ធផលរំពឹងទុកទី៤** *សមត្ថភាពក្រុមប្រឹក្សាសង្កាត់ និងបុគ្គលិកសង្កាត់នឹងត្រូវបានបង្កើន*

***សកម្មភាព១*** *ជ្រើសរើស និងបណ្តុះបណ្តាលក្រុមប្រឹក្សាសង្កាត់ និងបុគ្គលិកសង្កាត់ពីវិធីសាស្ត្រចុះស្រង់ស្ថិតិ និងចុះអង្កេត*

***សកម្មភាព២*** *ធ្វើទស្សនកិច្ចសិក្សាទៅប្រទេសឥណ្ឌូនេស៊ី និងប្រទេសថៃ*

# ការរៀបចំអ្នកលក់ដូរតាមដងផ្លូវ និងទីសាធារណៈ

## ទិសដៅដល់ឆ្នាំ ២០១១-២០១២ សម្រាប់សង្កាត់ចោមចៅដែលជាសង្កាត់សាកល្បង

| ទិសដៅ លទ្ធផល និង សកម្មភាព | ការបរិយាយ អំពីទិសដៅ និងទិសដៅសកម្មភាព និងពេលវេលា | ២០១១ | | | | ២០១២ | | | អ្នកទទួល ខុសត្រូវ | ឯកសារបញ្ជាក់ | តំលៃ ប៉ាន់ស្មាន ប្រភពថវិកា |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ត.ម.១ | ត.ម.២ | ត.ម.៣ | ត.ម.៤ | ត.ម.១ | ត.ម.២ | ត.ម.៣ | | | |
| **ទិសដៅ** | ចូលរួមលើកស្ទួយការវិនិយោគ លើកកម្ពស់គុណភាព ជីវិត និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងសង្កាត់ចោមចៅ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវសណ្តាប់ធ្នាប់ បរិស្ថាន សន្តិសុខ និងអនាម័យ តាមដងផ្លូវ និងតាមទីសាធារណៈ | | | | | | | | | -ភាគរយនៃចំនួនប្រជាពលរដ្ឋដែលពេញចិត្តនិងការធ្វើអោយប្រសើរឡើងនូវសេវានេះ<br>-ចំនួនទីផ្សារដែលបានរៀបបង្កើតឡើងថ្មី | |
| **គោលបំណង** | រៀបចំការលក់ដូរតាមផ្សារ តាមដងផ្លូវ និងទីសាធារណៈឱ្យមានសណ្តាប់ធ្នាប់<br>**យុទ្ធសាស្ត្រ**<br>● អប់រំ បណ្តុះបណ្តាល និង ផ្សព្វផ្សាយ ជំរុញការអនុវត្តការគ្រប់គ្រងផ្សារ<br>● ទទួលខុសត្រូវបង្កើតទីតាំងថ្មី និងអភិវឌ្ឍទីតាំងផ្សារដែលមានស្រាប់<br>● ធ្វើការផាកពិន័យ និងលើទឹកចិត្តដល់អ្នកដែលបានអនុវត្តល្អ | | | | | | | | | | |
| **លទ្ធផល រំពឹងទុក១** | *ទីតាំងអ្នកលក់ដូរអនាធិបតេយ្យ ត្រូវបានរៀបចំសមស្រប* | | | | | | | | ក្រុមប្រឹក្សាសង្កាត់ | ចំនួនទីផ្សារដែលបានរៀបចំ | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| **សកម្មភាព១.១** | **កំណត់ទីតាំងលក់ដូរដែលមានភាព អនាធិបតេយ្យ ស្រង់ស្ថិតិផ្សារក្នុងសង្កាត់ទាំងអស់** | | | | | | | | | | |
| | **ជំហ៊ាន ១**<br>ស្រង់ស្ថិតិផ្សារ ក្នុងសង្កាត់ទាំងអស់ | | | | | | | | មន្ត្រីសង្កាត់ | លទ្ធផលនៃការអង្កេត | $ 300<br>ថវិកា<br>សង្កាត់ |
| | **ជំហ៊ាន ២**<br>ជ្រើសរើស និង កំណត់អាទិភាព ទិតាំងផ្សារអនាធិបតេយ្យដែល ត្រូវរៀបចំ សណ្តាប់ធ្នាប់ សាកល្បង | | | | | | | | ក្រុមប្រឹក្សាសង្កាត់ | -ចំនួនទីផ្សារសាកល្បង<br>-កំណត់ហេតុប្រជុំ | $ 250<br>ថវិកា<br>សង្កាត់ |
| **សកម្មភាព១.២** | **ស្រង់ស្ថិតិអ្នកលក់ដូរចល័ត និង តាមរដូវកាល និងអំពីចំណូល ប្រចាំថ្ងៃរបស់អ្នកលក់ដូរ ទាំងនោះ អ្នករត់រម៉ក់ម៉ូតូ និងជួលមុខផ្ទះឱ្យ អ្នកលក់ចល័ត** | | | | | | | | | បញ្ជីឈ្មោះអ្នកលក់ចលត | |
| | ជ្រើសរើស និង បណ្តុះបណ្តាល អ្នកអង្កេត (១០ នាក់) រយះពេល២ថ្ងៃ | | | | | | | | ក្រុមប្រឹក្សាសង្កាត់ និងអ្នកសម្របសម្រួល | បញ្ជីឈ្មោះអ្នកចូលរួម | $ 250<br>ថវិកា<br>DELGOSEA |
| | | | | | | | | | | | |
| | បញ្ចូល និងវិភាគ ទិន្នន័យពី លទ្ធផលអង្កេត | | | | | | | | អ្នកជំនាញ | -បញ្ចូលទិន្នន័យ<br>-លទ្ធផលនៃការវិភាគ | $ 250<br>ថវិកា<br>DELGOSEA |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| **សកម្មភាព១.៣** | **កំណត់រកទីតាំង និងម្ចាស់ទីតាំង ផ្សារ (កន្លែងលក់ដូរ) ថ្មី និងមានតម្លៃសមស្រប** | | | | | | | | ក្រុមប្រឹក្សាសង្កាត់ | បញ្ជីទីតាំង និងឈ្មោះម្ចាស់ | |
| | សិក្សាអំពីទីតាំងសមស្របតាមចំនួនអ្នកលក់ដូរ | | | | | | | | ក្រុមប្រឹក្សាសង្កាត់ និងម្ចាស់ដី | លទ្ធផលនៃការសិក្សា | $ 550 ថវិកាសង្កាត់ |
| | ជួបប្រជុំជាមួយអ្នកពាក់ព័ន្ធ រួមមានអ្នកមានដី អ្នកលក់ដូរ | | | | | | | | ក្រុមប្រឹក្សាសង្កាត់ | -ចំនួនកិច្ចប្រជុំ<br>-លទ្ធផលនៃកិច្ចប្រជុំ | $ 550 ថវិកាសង្កាត់ |
| | រៀបចំគណៈកម្មការឬភ្នាក់ងារទទួលខុស ត្រូវ លើការងារសន្តិសុខ សណ្តាប់ធ្នាប់ និងអនាម័យ | | | | | | | | ក្រុមប្រឹក្សាសង្កាត់ | ចំនួននៃការសម្រេចចិត្ត | $ 250 ថវិកាសង្កាត់ |
| | ចរចារ និងកំណត់ លើតម្លៃឈ្នួល | | | | | | | | ក្រុមប្រឹក្សាសង្កាត់ | -កំណត់ហេតុប្រជុំ<br>-ចំនួននៃកិច្ចព្រមព្រៀង | $ 250 ថវិកាសង្កាត់ |
| | រៀបចំនិងកំណត់គោលការណ៍ ផាកពិន័យចំពោះការលក់ដូរតាមចិញ្ចៀមផ្លូវ | | | | | | | | ក្រុមប្រឹក្សាសង្កាត់ | ចំនួន និង កំណត់ត្រាគោលការណ៍ | $ 200 ថវិកាសង្កាត់ |
| **សកម្មភាព១.៤** | **ពិភាក្សាអំពីការវិនិយោគលើទីតាំងផ្សារថ្មី ជាមួយរដ្ឋបាលខណ្ឌ និងរាជធានី** | | | | | | | | | | $ 500 ថវិកាសង្កាត់ |
| **លទ្ធផល** | *តំលៃតូបនៅក្នុងផ្សារត្រូវបានកែសំរួល អាចទទួលយកបាន* | | | | | | | | ក្រុមប្រឹក្សាសង្កាត់ | កិច្ចព្រមព្រៀង | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| **រំពឹងទុក២** | | | | | | | | | | | |
| **សកម្មភាព២.១** | **កំណត់តំលៃសមស្រប** | | | | | | | | | | |
| | **ជំហ៊ាន ១**<br>ជួបប្រជុំជាមួយអ្នកគ្រប់គ្រងទីផ្សារ | | | | | | | | ក្រុមប្រឹក្សាសង្កាត់ | -ចំនួនប្រជុំ<br>-របាយការណ៏ លទ្ធផលប្រជុំ | $ 350<br>ថវិកា<br>សង្កាត់ |
| | **ជំហ៊ាន ២**<br>ជួបប្រជុំជាមួយអ្នកលក់ | | | | | | | | ក្រុមប្រឹក្សាសង្កាត់ | -ចំនួនប្រជុំ<br>-របាយការណ៏ លទ្ធផលប្រជុំ | $ 550<br>ថវិកា<br>សង្កាត់ |
| | ជំហ៊ាន ២<br>ជួបប្រជុំជាមួយអ្នកពាក់ពន្ធ័ទាំងអស់រួម<br>ទាំងរដ្ឋបាលខណ្ឌ និងរាជធានី | | | | | | | | | -ចំនួនប្រជុំ<br>-របាយការណ៏ លទ្ធផលប្រជុំ | $ 1500<br>ថវិកា<br>សង្កាត់ |
| **សកម្មភាព២.២** | **ពង្រីកទីតាំងផ្សារដែលមានស្រាប់ ដើម្បីទទួលយក អ្នកលក់ខាងក្រៅបន្ថែម** | | | | | | | | | | |
| | **ជំហ៊ាន ១**<br>កំណត់ចំនួនអ្នកលក់ដូរតាមផ្លូវដែលនៅ<br>ជិតផ្សារដែលមានស្រាប់ | | | | | | | | ក្រុមប្រឹក្សាសង្កាត់ | បញ្ជីឈ្មោះអ្នកលក់តាមចិញ្ចើមផ្លូវ | $ 250<br>ថវិកា<br>សង្កាត់ |
| | **ជំហ៊ាន ២**<br>រៀបចំប្រជុំ ធ្វើការឯកភាព<br>ក្នុងការរៀបចំបង្កើត និង ពង្រីកទីផ្សារ | | | | | | | | ក្រុមប្រឹក្សាសង្កាត់ | -ចំនួនប្រជុំ<br>-កំណត់ហេតុប្រជុំ | $ 550<br>ថវិកា<br>សង្កាត់ |
| | **ជំហ៊ាន ៣**<br>បញ្ចូលអ្នកលក | | | | | | | | ក្រុមប្រឹក្សាសង្កាត់ | -ចំនួនប្រជុំ<br>-កំណត់ហេតុប្រជុំ | $ 500<br>ថវិកា<br>សង្កាត់ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | តាមចិញ្ចៀមផ្លូវទៅក្នុងទីផ្សារ | | | | | | | | | | |
| **លទ្ធផល រំពឹងទុក៣** | *ទុន និងសមត្ថភាពត្រូវបានផ្តល់ដល់អ្នកលក់ដូរក្រីក្រ និងអ្នកខ្វះខាតទុន* | | | | | | | | | | |
| **សកម្មភាព៣.១** | **សិក្សារកទីតាំងសមរម្យសំរាប់លក់ដូរ** | | | | | | | | | | |
| | **ជំហ៊ាន ១** សិក្សារកទីតាំងសមរម្យសម្រាប់ទីផ្សារ | | | | | | | | ក្រុមប្រឹក្សាសង្កាត់ | របាយការណ៍ពីទិន័យ ត្រួតពិនិត្យគម្រោង | $ 350 ថវិកា សង្កាត់ |
| | **ជំហ៊ាន ២** រៀបចំប្រជុំ ធ្វើការឯកភាព របស់ម្ចាស់ដីទៅលើគម្រោង | | | | | | | | ក្រុមប្រឹក្សាសង្កាត់ | ចំនួននៃកិច្ចព្រមព្រៀង | $ 350 ថវិកា សង្កាត់ |
| | **ជំហ៊ាន ៣** ពិភាក្សាជាមួយរដ្ឋបាលខណ្ឌ និងរាជធានី ក្នុងការគាំទ្រ និងផ្តល់ការអនុញ្ញាតគម្រោង | | | | | | | | ក្រុមប្រឹក្សាសង្កាត់ | -ចំនួនប្រជុំ<br>-កំណត់ហេតុលទ្ធផលប្រជុំ | $ 500 ថវិកា សង្កាត់ |
| **សកម្មភាព៣.២** | **រៀបចំបង្កើតគណៈកម្មការ ទទួលខុសត្រូវៈ សន្តិសុខ សន្តាប់ធ្នាប់ អនាម័យ គ្រប់គ្រងសារពើពន្ធ** | | | | | | | | ក្រុមប្រឹក្សាសង្កាត់ | | |
| | **ជំហ៊ាន ១** បង្កើតគណៈកម្មការនានាដើម្បីគ្រប់គ្រង ផ្សារ | | | | | | | | | ចំនួនគណៈកម្មការដែលបានបង្កើត | $ 250 ថវិកា សង្កាត់ |
| | **ជំហ៊ាន ២** រៀបចំបែបបទការងារសម្រាបគណៈក | | | | | | | | ក្រុមប្រឹក្សាសង្កាត់ | ចំនួននៃសេចក្តីសម្រេច | $ 200 ថវិកា |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ម្មការ | | | | | | | | | | សង្កាត់ |
| | **ជំហ៊ាន ៣**<br>គារតាមដាន<br>ត្រួតពិនិត្យគម្រោងជាប្រចាំ | | | | | | | | អ្នកសម្របសម្រួល | របាយការណ៍ត្រួតពិនិត្យ | $ 1000<br>ថវិកា<br>DELGOSEA |
| **សកម្មភាព៣.៣** | **ផ្សព្វផ្សាយពតិមាន អប់រំ និងលើកទឹកចិត្តដល់អ្នកទិញឱ្យចូលទិញក្នុងផ្សារដែលមិនតាមចិញ្ចៀមផ្លូវ** | | | | | | | | | ចំនួននៃការផ្សព្វផ្សាយ | $ 1000<br>ថវិកា<br>សង្កាត់ |
| **សកម្មភាព៣.៤** | **ចរចារជាមួយម្ចាស់ទីតាំងដើម្បីបញ្ចុះ តម្លៃឈ្នួល** | | | | | | | | | ចំនួននៃកិច្ចប្រជុំ | $ 500<br>ថវិកា<br>សង្កាត់ |
| **សកម្មភាព៣.៥** | **បណ្តុះបណ្តាលស្តីពីការធ្វើជំនួញខ្នាតតូចដល់អ្នកពាក់ព័ន្ធ** | | | | | | | | | របាយការណ៍បណ្តុះបណ្តាល | $ 1500<br>ថវិកា<br>**និងបញ្ជាក់** |
| **លទ្ធផល<br>រំពឹងទុក៤** | **សមត្ថភាពរបស់មន្ត្រី និងស្ថាប័នពាក់ព័ន្ធកើនឡើង** | | | | | | | | | | |
| **សកម្មភាព៤.១** | **បណ្តុះបណ្តាលមន្ត្រី និងសមាជិកគណកម្មការ** | | | | | | | | | | |
| | **ជំហ៊ាន ១**<br>សិក្សាពីតម្រូវការបណ្តុះបណ្តាល | | | | | | | | អ្នកសម្របសម្រួល | របាយការណ៍សិក្សាពីតម្រូវការបណ្តុះបណ្តាល | $ 250<br>ថវិកា<br>DELGOSEA |
| | **ជំហ៊ាន ២**<br>បើវគ្គបណ្តុះបណ្តាលដែលពាក់ព័ន្ធ | | | | | | | | អ្នកសម្របសម្រួល | របាយការណ៍បណ្តុះបណ្តាល | $ 1500<br>ថវិកា<br>DELGOSEA |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | |
| **សកម្មភាព៤.២** | **ធ្វើទស្សនៈកិច្ចសិក្សានៅប្រទេសឥណ្ឌូនេស៊ី និងប្រទេសថៃ** | | | | | | | | | | |
| | **ជំហ៊ាន ១**<br>រៀបចំពេលវេលាជាមួយប្រទេសដែលទទួល | | | | | | | | អ្នកសម្របសម្រួល DELGOSEA | កាលវិភាគ | |
| | **ជំហ៊ាន ២**<br>ទស្សនកិច្ចសក្សា | | | | | | | | អ្នកសម្របសម្រួល DELGOSEA | របាយការណ៏ទស្សនកិច្ចសិក្សា | $ 8500 ថវិកា សង្កាត់ និង DELGOSEA |
| | **ជំហ៊ាន ៣**<br>វាយតម្លៃទស្សនកិច្ចសក្សា និងប្រមូលបទពិសោធន៍ | | | | | | | | ក្រុមប្រឹក្សាសង្កាត់ និង អ្នកសម្របសម្រួល | -របាយការណ៏វាយតម្លៃ កំណត់ហេតុនៃសិក្ខាសាលាឆ្លុះបញ្ចាំង | $ 300 DELGOSEA |
| | | | | | | | | | | | |